*គណៈកម្មការឱកាសការងារស្មើភាពសហរដ្ឋអាមេរិក*

# ការបង្ការការរើសអើងគឺជាអាជីវកម្មមួយដ៏ល្អ

***ការបង្ការការរើសអើងបង្កើតបានជាការយល់ដឹងពីអាជីវកម្មដ៏ល្អ ។*** ការអនុវត្តតាមច្បាប់អាចបង្កើនផលិតភាពបុគ្គលិក ការរក្សាទុក និងទឹកចិត្ត និងកំណត់ការចំណាយផ្នែកច្បាប់ ។ អ្នកអាចសូម្បីមានសិទ្ធិទទួលអត្ថប្រយោជន៍ពន្ធសម្រាប់ការជួលបុគ្គលម្នាក់ៗដែលមានពិការភាព ឬការធ្វើឱ្យអាជីវកម្មរបស់អ្នកអាចទទួលបានពីសំណាក់ជនពិការ! សូមមើល http://www.eeoc.gov/eeoc/publications/adahandbook.cfm#appendixa សម្រាប់ព័ត៌មានបន្ថែម ។

***EEOC អាចជួយដល់ម្ចាស់អាជីវកម្មខ្នាតតូច!*** EEOC គឺជាទីភ្នាក់ងាររដ្ឋាភិបាលសហព័ន្ធដែលដាក់ឱ្យអនុវត្តច្បាប់សហព័ន្ធប្រឆាំងនឹងការរើសអើងការងារដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ សាសនា ភេទ ដើមកំណត់ជនជាតិ ពិការភាព អាយុ និងព័ត៌មានអំពីហ្សែន ។ ច្បាប់ទាំងនេះហាមឃាត់លើការសងសឹក (ការដាក់ទណ្ឌកម្ម) សម្រាប់ការជំទាស់ ឬការរាយការណ៍ពីការរើសអើង ឬការចូលរួមក្នុងការស៊ើបអង្កេតការរើសអើង ឬពាក្យបណ្តឹង ។

## ការទទួលខុសត្រូវរបស់អ្នក

- **ធានាថា ការសម្រេចចិត្តការងារ** គឺមិនផ្អែកលើពូជសាសន៍ ពណ៌សម្បុរ សាសនា ភេទ ដើមកំណើតជនជាតិ ពិការភាព អាយុ ឬព័ត៌មានអំពីហ្សែន ។
- **ធានាថា គោលការណ៍ការងារ និងការអនុវត្ត** គឺមិនទាក់ទងទៅនឹងការងារ ហើយមិនផាត់ចេញនៃពូជសាសន៍ ពណ៌សម្បុរ សាសនា ភេទ ដើមកំណើតជនជាតិ ពិការភាព ឬអាយុជាក់លាក់ដោយមិនស្មើគ្នាឡើយ ។
- **ធានាថា បុគ្គលិកមិនត្រូវបានយាយី** ដោយសារតែពូជសាសន៍ ពណ៌សម្បុរ សាសនា ភេទ ដើមកំណើតជនជាតិ ពិការភាព អាយុ ឬព័ត៌មានអំពីហ្សែនឡើយ ។
- **ផ្តល់ប្រាក់ខែស្មើគ្នារវាងបុគ្គលិកបុរស និងស្ត្រីដែលបំពេញការងារដូចគ្នា** លុះត្រាតែអ្នកអាចផ្តល់ហេតុផលត្រឹមត្រូវពីភាពខុសគ្នានៃប្រាក់ខែស្ថិតក្រោមច្បាប់ ។
- **ឆ្លើយតបឆាប់រហ័ស និងគ្រប់គ្រាន់ចំពោះបណ្តឹងលើការរើសអើង ។** បញ្ឈប់ បង្ហាញ និងទប់ស្កាត់ការយាយី និងការរើសអើង ។ ធានាថា បុគ្គលិកមិនត្រូវបានផ្តន្ទាទោសចំពោះការតវ៉ា ។
- **ផ្តល់កន្លែងស្នាក់នៅសមរម្យ** (ផ្លាស់ទៅរកវិធីដែលរឿងរ៉ាវត្រូវបានធ្វើជាធម្មតានៅកន្លែងធ្វើការ ដូចជាការអនុញ្ញាតឱ្យផ្លាស់ប្តូរកាលវិភាគ ដើម្បីឱ្យបុគ្គលិកអាចធ្វើការណាត់ជួបជាមួយគ្រូពេទ្យ ឬអាចឈប់សម្រាកសម្រាប់បុណ្យសាសនា) **ចំពោះអ្នកដាក់ពាក្យ និងបុគ្គលិកដែលត្រូវការវាសម្រាប់ហេតុផលវេជ្ជសាស្ត្រ ឬសាសនា** បើមានតម្រូវការដោយច្បាប់ ។
- **បង្ហាញផ្ទាំងរូបភាព** ដែលពិពណ៌នាពីច្បាប់លើការរើសអើងការងារសហព័ន្ធ ។ (ទាញយកវាមួយដោយឥតគិតថ្លៃនៅ http://www1.eeoc.gov/employers/poster.cfm) ។
- **រក្សាកំណត់ត្រាការងារនានា** (ដូចជា បែបបទដាក់ពាក្យសុំ ឬកំណត់ត្រាផ្ទាល់ខ្លួន) ដែលមានត្រូវការដោយច្បាប់ ។

អ្នកអាចមានទំនួលខុសត្រូវបន្ថែមស្ថិតក្រោមច្បាប់សហព័ន្ធរដ្ឋ ឬច្បាប់ក្នុងតំបន់ ។

## របៀបដែលយើងអាចជួយ

- **យើងអាចឆ្លើយសំណួរផ្សេងៗរបស់អ្នក** អំពីច្បាប់ដែលយើងដាក់ឱ្យអនុវត្ត ។
- **យើងអាចផ្តល់សំណើនានា** ដើម្បីជួយអ្នកបង្ការការយាយី ការសងសឹក និងទម្រង់ផ្សេងទៀតនៃការរើសអើងដែលផ្ទុយនឹងច្បាប់ ។
- **យើងអាចបណ្តុះបណ្តាលអ្នក និងបុគ្គលិករបស់អ្នក**អំពីសិទ្ធិ និងទំនួលខុសត្រូវនៅកន្លែងធ្វើការ ។
- **យើងអាចជួយអ្នកដោះស្រាយលើបទចោទប្រកាន់ (បណ្តឹង) EEOC នៃការរើសអើង**តាមរយៈការសម្រុះសម្រួល ។ ការសម្រុះសម្រួលគឺជាដំណើរការឥតគិតថ្លៃ ក្រៅផ្លូវការ ជាការសម្ងាត់ដើម្បីដោះស្រាយជម្លោះនានា ដែលអាចសន្សំសំចៃពេលវេលា និងប្រាក់កាសរបស់អ្នក ។

## ទាក់ទងពួកយើង!

**បុគ្គលិក EEOC នៅទូទាំងប្រទេសគឺអាចរកបានសម្រាប់ជួយអ្នក ។ កុំបារម្ភ ។ ទាក់ទងមកយើងថ្ងៃនេះ!**
ជំនួយខាងភាសាឥតគិតថ្លៃគឺអាចរកបាន ប្រសិនបើចាំបាច់ ។

- ***ត្រូវការព័ត៌មាន ឬការបណ្តុះបណ្តាល EEOC?***

ទាក់ទងសម្ព័ន្ធអាជីវកម្មខ្នាតតូច EEOC ក្នុងតំបន់របស់អ្នក (http://www.eeoc.gov/employers/contacts.cfm) ឬ ទូរស័ព្ទមកយើងតាមលេខ 1-800-669-4000 (TTY: 1-800-669-6820) ។

- ***ត្រូវការព័ត៌មានអំពីច្បាប់ដែលយើងដាក់ឱ្យអនុវត្ត?***

ទូរស័ព្ទមកយើងតាមលេខ (202) 663-4691 ឬផ្ញើអ៊ីម៉ែលមកយើងនៅ olc@eeoc.gov ។

- ***មានសំណួរផ្សេងៗអំពីបទចោទប្រកាន់ EEOC នៃការរើសអើងប្រឆាំងនឹងអាជីវកម្មរបស់អ្នក?***

ទាក់ទងអ្នកស៊ើងអង្កេត EEOC ដែលចាត់តាំងចំពោះបទចោទប្រកាន់របស់អ្នក ។

យើងទន្ទឹងរង់ចាំដឹងដំណឹងពីអ្នក!

សម្រាប់ព័ត៌មានបន្ថែម ទាក់ទងសម្ព័ន្ធអាជីវកម្មខ្នាតតូច EEOC ក្នុងតំបន់របស់អ្នក (http://www.eeoc.gov/employers/contacts.cfm) ។